## ព្រះរាជក្រឹត្យ នស/រកត/០៩៩៩/១៧៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ រាជាវរ័ន្ត

ឧត្តមោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .-តែងតាំងលោកឧត្តម ពេជ្រ សុវជេតា ជាទីប្រឹក្សារបស់ឯកឧត្តម ទុល ឡាះ ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ .-នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .-ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៨៣ អនក្រ/បក

### ស្ដីពីការកំណត់ទំងន់ អតិបរមា នៃយានយន្តដឹកជញ្ជូនផ្លូវគោក ដែលបើកបរលើបណ្ដាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន ។

-បានឃើញក្រឹត្យលេខ ៦៩ ក្រ ចុះថ្ងៃទី៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរ ផ្លូវគោក

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ១៩៩៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ការគ្រប់គ្រងទំងន់យានយន្តដឹកជញ្ជូនទំនិញតាមបណ្តាញផ្លូវជាតិទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅធានាភាពស្ថិតស្ថេររបស់ផ្លូវថ្នល់អោយបានយូរអង្វែងស្រប តាមបច្ចេកទេស នៃការស្ថាបនាផ្លូវថ្នល់ ។

## ជំពូកទី២

## និយមន័យ " ពាក្យបច្ចេកទេស " ដែលប្រើក្នុងអនុក្រឹត្យ

**មាត្រា ២ .-** ត្រូវបានហៅថា :

- រថយន្តដឹកជញ្ជូន : សំដៅរថយន្តដែលមានម៉ាស៊ីនភ្ជាប់ជាមួយភ្លៅរថយន្ត គឺអ័ក្សរបស់រថយន្ត ដែលភ្ជាប់ដោយកង់រថយន្តខាងឆ្វេង និងខាងស្តាំ ។ កង់នោះអាចជាកង់សាមញ្ញ ឬកង់ភ្លោះ ។
- ភ្លៅទោល : គឺជាភ្លៅរថយន្តដែលមានចំងាយយ៉ាងតិច ១,៨០ ម៉ែត្រ ពីភ្លៅមួយទៀត ។
- ភ្លៅឌុប : សំដៅភ្លៅរថយន្តពីរនៅចំងាយពីគ្នាយ៉ាងតិចជាង ១,៨០ ម៉ែត្រ និងឆ្ងាយជាង១,៣០ម៉ែត្រ ។
- រឺម៉ក : សំដៅយានសំរាប់ផ្ទុកទំនិញគ្មានម៉ាស៊ីនភ្ជាប់ជាមួយ ហើយត្រូវអូសសណ្តោងដោយរថយន្តដឹកជញ្ជូន ។
- យានយន្តដឹកជញ្ជូន : គឺសំដៅរថយន្តដឹកជញ្ជូនទាំងរឺម៉ក ដែលរថយន្តនោះសណ្តោង ។
- ទំងន់សរុបរបស់យានយន្តដឹកជញ្ជូន : គឺជាទំងន់របស់រថយន្ត រឺម៉ក និងទំនិញផ្ទុក ។

- ក្រុមបណ្តាញផ្លូវជាតិប្រភេទ (ក) : ផ្លូវជាតិលេខ៤ លេខ៦ លេខ៧ ពីផ្លូវបំបែកស្គន់ ទីរួមខេត្តកំពង់ចាម ។
- ក្រុមបណ្តាញផ្លូវជាតិប្រភេទ (ខ) : ផ្លូវជាតិផ្សេងៗទៀត ។

## ជំពូកទី៣
## កំរិតកំណត់ទំងន់ អតិបរមាលើភ្លៅ យានយន្តដឹកជញ្ជូន

**មាត្រា ៣ .-**

ត្រូវបានកំណត់ត្រឹម១០តោន ទំងន់អតិបរមានៃភ្លៅទោលនៃយានយន្តដឹកជញ្ជូនដែលចរាចរនៅលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ .-**

ត្រូវបានកំណត់ត្រឹម១៨តោន ទំងន់អតិបរមានៃភ្លៅឌុបយានយន្តដឹកជញ្ជូនដែលចរាចរនៅលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។ ទំងន់នីមួយៗ នៃភ្លៅឌុបមិនត្រូវអោយលើសពី ១០តោន ស្របតាម មាត្រា៣ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៤
## កំរិតកំណត់ទំងន់ អតិបរមា យានយន្តដឹកជញ្ជូន
## អនុញ្ញាតអោយធ្វើចរាចរតាមក្រុមបណ្តាញផ្លូវជាតិ ប្រភេទ (ក)

**មាត្រា ៥ .-**

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្តាញផ្លូវជាតិប្រភេទ (ក) ត្រូវបានកំណត់អតិបរមាដូចតទៅ :

១-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ ២ កំរិតទំងន់ជាអតិបរមា អនុញ្ញាតពី ១៦តោន ។

២-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ ៣ កំរិតទំងន់ជាអតិបរមា អនុញ្ញាតពី ២៥ តោន ។

ភ្លៅរថយន្តក៏ត្រូវអោយស្របមាត្រា ៣ និង មាត្រា ៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦ .-**

ទំងន់សរុបអតិបរមារបស់យានយន្តដឹកជញ្ជូនមានសណ្តោងរ៉ឺម៉ក ត្រូវបានអនុញ្ញាតដូចខាងក្រោមនេះ :

១-ចំពោះយានយន្តដែលមានភ្លៅ ៤ ទំងន់សរុបអតិបរមាអនុញ្ញាតអោយចរាចរពី ៣៥តោន ។

២-ចំពោះយានយន្តដែលមានភ្លៅ ៥ ទំងន់សរុបអតិបរមាអនុញ្ញាតអោយចរាចរពី ៤០តោន ។

ទំងន់សរុបនេះក៏ត្រូវអោយស្របមាត្រា ៣ មាត្រា ៤ និងមាត្រា ៥ ហើយទំងន់សរុបរបស់រ៉ឺម៉ក មិនត្រូវអោយធ្ងន់ជាង ៣០% (ភាគរយ) ពីទំងន់សរុប នៃរថយន្តដឹកជញ្ជូនដែលអូសសណ្តោងនោះ ។

## ជំពូកទី៥
## កំរិតកំណត់ទំងន់ អតិបរមា យានយន្តដឹកជញ្ជូន
## អនុញ្ញាតអោយធ្វើចរាចរតាមក្រុមបណ្តាញផ្លូវជាតិ ប្រភេទ (ខ)

មាត្រា ៧ .-

ទំងន់រថយន្តដឹកជញ្ជូន ដែលធ្វើចរាចរតាមក្រុមបណ្តាញផ្លូវជាតិដូចបានចែងខាងលើ ត្រូវបានកំណត់ជាអតិបរមាដូចតទៅ :

១-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ ២ កំរិតទំងន់ជាអតិបរមា អនុញ្ញាតគឺ ១៦តោន ។

២-ចំពោះរថយន្តដឹកជញ្ជូនដែលមានភ្លៅ ៣ កំរិតទំងន់ជាអតិបរមា អនុញ្ញាតគឺ ២០ តោន ។

ភ្លៅរថយន្តក៏ត្រូវអោយគោរពមាត្រា ៣ និង មាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា ៨ .-

ទំងន់សរុបអតិបរមារបស់រថយន្តដឹកជញ្ជូន មានសណ្តោងរ៉ឺម៉ក ត្រូវបានអនុញ្ញាតដូចខាងក្រោមនេះ:

១-ចំពោះរថយន្តដែលមានភ្លៅ ៤ ទំងន់សរុបអតិបរមាអនុញ្ញាតអោយចរាចរគឺ ៣០តោន ។

២-ចំពោះរថយន្តដែលមានភ្លៅ ៥ ទំងន់សរុបអតិបរមាអនុញ្ញាតអោយចរាចរគឺ ៣៥តោន ។

ទំងន់សរុបនេះក៏ត្រូវអោយគោរពមាត្រា ៣ មាត្រា ៤ និងមាត្រា ៧ ដូចមានចែងខាងលើ ហើយទំងន់សរុបរបស់រ៉ឺម៉ក មិនត្រូវអោយធ្ងន់ជាង ៣០% (ភាគរយ) ពីទំងន់សរុបនៃរថយន្តដឹកជញ្ជូនដែលអូសសណ្តោង ។

ទំងន់ដូចបានកំណត់ក្នុងចំណុចខាងលើនេះ អាចនឹងកែប្រែបានដោយប្រកាសរបស់ក្រសួង ។

## ជំពូកទី៦
## បទប្បញ្ញត្តិដោយឡែក

មាត្រា ៩ .-

កំរិតកំណត់លំអិត ស្តីពីទំងន់យានយន្តអនុញ្ញាតចំពោះប្រភេទយានយន្តដឹកជញ្ជូននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

មាត្រា ១០ .-

ចំពោះការដឹកជញ្ជូនពិសេស ដែលមានទំងន់លើសពីកំរិតទំងន់ដែលបានចែងក្នុងអនុក្រឹត្យនេះ ហើយដែលមានលក្ខណៈចាំបាច់ និងប្រព្រឹត្តឡើងម្តងម្កាល ម្ចាស់រថយន្តត្រូវធ្វើពាក្យសុំអនុញ្ញាតអំពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីពិនិត្យនិងសំរេច ។

មាត្រា ១១ .-

យានយន្តដឹកជញ្ជូនទាំងឡាយណា ដែលមានប្រភេទខុសប្លែកពីប្រភេទដូចបានចែងក្នុងអនុក្រឹត្យនេះ ត្រូវធ្វើសំណើរសុំការអនុញ្ញាតធ្វើចរាចរពីក្រសួងសាធារណការនិងដឹកជញ្ជូន ជាមុន ។

**មាត្រា ១២ .-**

ការគិតពន្ធគយលើទំនិញអនុញ្ញាតឲ្យនាំចូល ដែលមានរបាយការណ៍ត្រួតពិនិត្យ គឺជាតម្លៃទំនិញអនុញ្ញាតនៃរបាយការណ៍មុនការដឹកជញ្ជូន ដោយមិនគិតពីតម្លៃក្នុងវិក្កយបត្រ ។

**មាត្រា ១៣ .-**

ក្នុងករណីពិសេស ដែលសេចក្តីតម្រូវការផ្លូវការពិតប្រាកដមុនការត្រួតពិនិត្យ ហើយការផ្តល់ការអនុញ្ញាតត្រួតពិនិត្យមានទៅតាមគោលការណ៍ ដើម្បីនាំទំនិញអនុញ្ញាតចូលបានភ្លាមៗនោះ ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច ត្រូវជាអ្នកផ្តល់សេចក្តីអនុញ្ញាតលើទំនិញអនុញ្ញាតចំពោះករណីនោះ ហើយត្រូវធ្វើការត្រួតពិនិត្យក្រោយការដឹកជញ្ជូន ។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា ១៤ .-**

ការផាកពិន័យ ត្រូវធ្វើតាមការកំណត់ដូចតទៅនេះ :

១-ចំពោះទំនិញនាំចូលដែលលើសពីការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨ តិចជាង ៥% ត្រូវធ្វើការប្រកាសជាលាយលក្ខណ៍អក្សរដោយមិនផាកពិន័យ ។

២-ចំពោះទំនិញនាំចូលដែលលើសពីការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨ ចាប់ពី ៥% ទៅ ១០% ត្រូវពិន័យជាប្រាក់ ១០០.០០០រៀល (មួយរយពាន់រៀល)

៣-ចំពោះទំនិញនាំចូលដែលលើសពីការអនុញ្ញាត ដែលចែងក្នុងមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨ ពី ១០% ឡើងទៅ ត្រូវពិន័យជាប្រាក់ ១០០.០០០រៀល (មួយរយពាន់រៀល) គុណនឹងទំនិញលើស ១តោន ។ ទំនិញលើសនេះ ពិត្រូវគិតទំនិញជាក់ស្តែង នៃទំនិញដែលអនុញ្ញាត ។

**មាត្រា ១៥ .-**

អ្នកនាំចូលទំនិញដែលត្រូវទទួលពិន័យដូចមានចែងក្នុងមាត្រាខាងលើនេះ មិនត្រូវបានអនុញ្ញាតនាំចូលបន្តទៀតទេ មុននឹងបានបង់ពន្ធលើទំនិញលើស និងបង់ប្រាក់ផាកពិន័យ ។ ភ្នាក់ងារដែលប្រព្រឹត្តក្នុងការធ្វើសេចក្តីសម្រេចនាំចូលទំនិញលើសនេះ ដើម្បីបន្លំទំនិញលើសពីការអនុញ្ញាតនេះ ត្រូវទទួលខុសត្រូវ ។

**មាត្រា ១៦ .-**

ក្នុងករណីការដឹកជញ្ជូនលើសពីការកំណត់ បណ្តាលមកពីមានការខូចខាតដល់ប្រព័ន្ធសម្ភារៈជាក់ស្តែង ម្ចាស់ទំនិញត្រូវសងការខូចខាតនោះដល់រដ្ឋវិញ បន្ថែមពីលើប្រាក់ពិន័យ ។

**មាត្រា ១៧ .-**

ប្រាក់ដែលបានមកពីការពិន័យ ត្រូវបង់ចូលថវិកាជាតិ៦០% និងប្រាក់៤០% ត្រូវបានអនុញ្ញាតធ្វើជារង្វាន់លើកទឹកចិត្តដល់អាជ្ញាធរមានសមត្ថកិច្ច ដែលបានបំពេញភារកិច្ចរបស់ខ្លួន ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ១៨ .-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុងដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

ស ខេង

★★★

## អនុក្រឹត្យ លេខ ៥០២ អនក្រ/តត
## ស្តីពីការតែងតាំង រដ្ឋមន្ត្រីទទួលបន្ទុកការងារវិនិយោគកម្ពុជា សំរាប់អាស៊ាន

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីកាបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលជាការកែតំរូវលើអនុក្រឹត្យលេខ ៥១ អនក្រ-បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា